ត-270

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយនិពន្ធខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនវិចិត្រមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកនិពន្ធសាសនា: លោកអាចារ្យ ពៅ-ស៊ុំ អ្នកគ្រូគរុ
សិស្សនៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

ផ្នែកអក្សរសាស្ត្រ ... ទំព័រ

លោកអាចារ្យ ពៅ-ស៊ុំ ..... វិធុរធម្មទេសនា គណ្ឌទី ១៥ ........ ១
លោកអាចារ្យ ឈឹម-ស៊ុំ ..... " " ១៦ ........ ១៤
ព្រះមហា សោម-ឡុច ..... " " ១៧ ........ ២៩
លោក សង់-ហង់វីហ្វាប .... អំពីដំណើរជីវិតនៃសត្វល្អិតៗ ........ ៣៦
អ្នកឧកញ៉ាពស្តុកវិនិច្ឆ័យ កែវ-ហង្ស ប្រលោមចិត្ត (ពាក្យកាព្យ) ........ ៥៨
អ្នកឧកញ៉ាវង្សាសារពេជ្ញ (ឧង).. លោកនេយ្យ ពាក្យកាព្យ (តមក) .... ៧៩
ឃុនវិចិត្រមន្ត្រី ញ៉ុក-ថែម ..... ពង្សាវតារប្រទេសចិន ........... ១០៥

ផ្នែកសាសនា

ដំណឹងអំពីក្រសួងធម្មការ ..... បញ្ជីរាយនាមមន្ត្រីសង្ឃនិងចៅអធិការ ដែល
ទើបតាំងឡើងថ្មី .............. ១២៤
" " ...... បុណ្យបញ្ចុះសីមានៅវត្តនាគ ........ ១២៩
ឃុនវិចិត្រមន្ត្រី ញ៉ុក-ថែម .... ប្រវត្តិសង្ខេបបញ្ចមសង្គាយនា(តមកនឹងចប់). ១៣៧
" " ...... ប្រវត្តិព្រះមហាកច្ចាយនត្ថេរ ........ ១៣៦
[illegible]អាចារ្យ ឈឹម-ស៊ុំ .... ពុទ្ធឃោសប្បវត្តិ ........... ១៤៣

[illegible]ទី ១៥ លេខ ១-២-៣ ប្រចាំខែយ៉ាំងវីយេ- ហ្វេវ្រីយេ- ម៉ារ្ស ១៩៤៣ ។

ដំឡៃផារ ១ ច្បាប់ ១០:០០ ។

វិទ្យុធម្មទេសនា លើកទី ១៦

## របស់ព្រះអាចារ្យ ឈឹម-ស៊ុម សទ្ធម្មប្បញ្ញោ

*សាចារ្យបង្រៀននៅសាលាបាលីជាន់ខ្ពស់ ភ្នំពេញ*

សំដែងពីថ្ងៃសៅរ៍ ៨កើត បឋមាសាឍ ឆមីចត្វាស័ក ព.ស. ២៤៩៥ (២០ យ្សុំង ១៩៥២)

### ធម្មាធម្មកថា

សំដែងពីធម៌ត្រូវធម៌ខុស

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*អាត្មៈនេះសូមសំដែងអំពីធម៌ត្រូវ ធម៌ខុស និងអំណោយផលនៃធម៌ត្រូវ ធម៌ខុសនោះ តាមបទបាលីពុទ្ធភាសិតថា*

ន ហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ

អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតិំ ។

*ប្រែថា សភាវៈទាំងឡាយ ២ ប្រការគឺ ធម្មៈ បានដល់ធម៌ត្រូវ១ អធម្មៈ បានដល់ធម៌ខុស១ ឲ្យផលពុំស្មើគ្នាទេ, ធម៌ខុសរមែងនាំសត្វទៅកាន់នរក, ធម៌ត្រូវរមែងនាំសត្វទៅកាន់សុគតិ ។*

*បណ្ដាពាក្យទាំង ២ យ៉ាងនេះ, សូមអធិប្បាយអំពីពាក្យថាធម៌ត្រូវជាមុន ។ ធម៌ត្រូវចែកចេញជា ៣ ប្រការគឺ:*

**បរិយត្តិធម៌** *បានដល់ធម៌សម្រាប់សិក្សា សម្រាប់ស្ដាប់គឺ ព្រះត្រៃបិដក ដែលចែកចេញជាព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម ឬហៅថា*

នវង្គសត្ថុសាសនៈ ពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាប្រកបដោយអង្គ ៩ គឺ: សុត្តៈ គេយ្យៈ, វេយ្យាករណៈ, គាថា, ឧទានៈ, ឥតិវុត្តកៈ ជាតកៈ, អព្ភូតធម្មៈ, វេទល្លៈ ។

បដិបត្តិធម៌ ធម៌សម្រាប់ប្រតិបត្តិតាម បានដល់អដ្ឋង្គិកមគ្គ ដែលជាផ្លូវនៃសេចក្តីប្រតិបត្តិប្រកបដោយអង្គ ៨ ប្រការគឺ សម្មាទិដ្ឋិ សេចក្តីយល់ត្រូវ១, សម្មាសង្កប្បោ សេចក្តីត្រិះរិះត្រូវ១, សម្មាវាចា វាចាត្រូវ១, សម្មាកម្មន្តោ ការងារត្រូវ១, សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ១, សម្មាវាយាមោ សេចក្តីព្យាយាមត្រូវ១, សម្មាសតិ ស្មារតីត្រូវ១, សម្មាសមាធិ ចិត្តដំកល់ត្រូវ១ ។

បដិវេធធម៌ ធម៌គឺការត្រាស់ដឹង បានដល់លោកុត្តរធម៌គឺមគ្គ ៤ មានសោតាបត្តិមគ្គជាដើម, ផល ៤ មានសោតាបត្តិផលជាដើម ។

ធម៌ត្រូវទាំង ៣ ផ្នែកនេះ ជាបច្ច័យឲ្យកំឡាំងដ៏ត ៗ គ្នា គឺបរិយត្តិធម៌ បើកុលបុត្របានសិក្សា បានស្តាប់ដោយការយកចិត្តទុកដាក់ហើយ ; ជាពន្លឺភ្លឺនាំឲ្យយល់ច្បាស់នូវផ្លូវនៃសេចក្តីប្រតិបត្តិ ដែលហៅថា បដិបត្តិធម៌; កាលបើដំណើរកាយវាចាចិត្តប្រព្រឹត្តត្រង់ទៅតាមបដិបត្តិធម៌ហើយ , ជាហេតុឲ្យកើតសេចក្តីត្រាស់ដឹង គឺបដិវេធធម៌ជាលំដាប់ ។

បរិយត្តិធម៌ទី ១ មិនមែនឲ្យផលត្រឹមតែយល់ផ្លូវប្រតិបត្តិប៉ុណ្ណោះទេ បើកុលបុត្តសិក្សា ឬស្ដាប់ឲ្យបានសេចក្ដីចេះចាំជាប្រាកដហើយ, ជាគុណមានអានុភាពអាចនាំផលប្រយោជន៍ច្រើន មកប្រគល់ដល់កុលបុត្តអ្នកសិក្សា អ្នកស្ដាប់នោះតាំងពីក្នុងបច្ចុប្បន្នទៀងទៅជាប្រាកដ; គឺកុលបុត្តអ្នកទ្រទ្រង់បរិយត្តិធម៌ រមែងបានលាភសក្ការៈដោយងាយ, រមែងមានមិត្តទាំងឡាយមូលមករាប់រកគ្រប់ទិស, រមែងបានសេចក្ដីសុខសាន្តក្នុងចិត្តឥតក្ដៅក្រហាយ, រមែងបង្កើតបុណ្យទាំងឡាយដែលជាស្បៀងទៅខាងបរលោក, លុះរំលាយខន្ធអំពីឥធលោកនេះបានទៅកើតក្នុងឋានសួគ៌ទេវលោក ឬសម្រេចដល់ឋានសិវមោក្ខគឺព្រះនិព្វានជាប្រាកដពុំខាន ។ អស់លោកទាំងឡាយប្រហែលជាបានឃើញដោយជាក់ស្ដែងថា : បរិយត្តិធម៌ អាចជ្រោងស្ទួយកុលបុត្តដែលទ្រទ្រង់ដោយហ្មត់ចត់ ឲ្យអណ្ដែតផុតពីទីទាបទៅដំកល់លើដំណែងដ៏ខ្ពង់ខ្ពស់បាន, ដូចយ៉ាងកុលបុត្តខ្លះ ដែលកើតក្នុងត្រកូលថោកទាបសោះទេ, ប៉ុន្តែបានសិក្សាបរិយត្តិធម៌ជ្រៅជ្រះ, ធម៌នោះអាចឈោងទាញប្រមូលយកបណ្ដាជនដទៃអំពីទីតំបន់ផ្សេងៗឲ្យចូលមករាប់អានកុលបុត្តនោះឯងដោយសេចក្ដីគោរព, ឲ្យចូលមកទទួលយ៉មខ្លួនជាអ្នកស្ដាប់បង្គាប់កុលបុត្តនោះដោយស្មោះអស់ពីចិត្ត; ហេតុដូច្នោះបានជាមានសុភាសិតជាសេចក្ដីឧបមាលោកប្រៀបទុកមកថា

ស្បង្កឹផសេតុប្បលរត្តុប្បល លូតលាស់ផុះផុលពីក្នុងភក់
ផុតផែនប្រថពីទឹកត្រក់ គន្ធិតក្រុកក្រឹបកេសរ ៗ

នេះជាគួរឧបមាថា: មនុស្សជាតិគ្រប់គ្នា ទោះបីកើតក្នុងត្រកូលថោកទាបយ៉ាងណាក៏ដោយ ឲ្យតែបានប្រតិបត្តិធម៌ដោយមុតមាំ ក៏ប្រាកដជានឹងបានជាទីនិយមរាប់អាននៃជនានុជនច្រើនគ្នា, ដូចជាផ្កាឈូកទុកណាជាដុះក្នុងភក់ទីត្រពាំងមិនស្អាតយ៉ាងណាក៏ដោយ ឲ្យតែលូតចេញផុតពីភក់មក ប្រាកដជាទីត្រូវការនៃភមរជាតិទាំងឡាយមានកន្ទន់, ម្រោម, ឃ្មុំ ជាដើម ដូច្នោះឯង ៗ នេះត្រឹមតែកុលបុត្តដែលកើតក្នុងត្រកូលថោកទាបផង ម្តេចក្នុងបណ្តាជនស្រឡាញ់ប្តូរចិត្តគំនិត ថ្វាយអាយុជីវិតដល់ម៉្លេះទៅហើយ, តាំងបាច់និយាយថ្វីឡើយ ដល់កុលបុត្តដែលកើតក្នុងត្រកូលខ្ពង់ខ្ពស់ស្រាប់ ៗ បើប្រសិនជាមានកុលបុត្តរបស់មហាត្រកូលណាមួយសិក្សាប្រតិបត្តិធម៌ឲ្យច្បាស់លាស់ ប្រតិបត្តិតាមឲ្យត្រឹមត្រូវដល់គំរិត ម្ល៉េះសមបណ្តាជនស្រឡាញ់ស្ញប់ចិត្តឥតរើសរួសឡើយ ហើយប្រហែលជាឥតមានមនុស្សពាលនៅឲ្យទើសទែងក្នុងស្រុកក្នុងប្រទេសទេ ៗ

ក្នុងឧបមាខាងដើមនេះ មានសេចក្តីសមគួរនឹងរឿងនិទាន ដែលព្រះគន្ថរចនាចារ្យរៀបរៀងទុកមកថា: កាលព្រះសព្វញ្ញូបរមគ្រូជាម្ចាស់ បានត្រាស់ហើយទ្រង់ត្រាច់ប្រកាសព្រះពុទ្ធសាសនា ទ្រង់ស្តេចទៅដល់

នគរកោសម្ពី ជារាជធានីនៃព្រះបាទឧទេន, មានទាសីម្នាក់ខ្នងគមឈ្មោះ នាងខុជ្ជុត្តរា ដែលនាងសាមាវតីជាអគ្គមហេសីនៃព្រះបាទឧទេន បានប្រើឲ្យទៅទិញផ្កា ចេញដំណើរទៅស្រាប់តែបានជួបប្រទះនឹងព្រះអង្គកំពុងសំដែងធម៌ទេសនា នាងបានចូលទៅស្តាប់អស់វេលាជាច្រើន, បានចាំជាក់គ្រប់បទល្មមសំដែងប្រាប់គេតទៅទៀតកើត ទើបហួសទៅទិញផ្កាយកមកជូននាងសាមាវតីជាខាងក្រោយ ដោយដំណើរយឺតយូរហួសកាលវេលា ។ នាងសាមាវតីបន្ទោសថា ម្តេចហ្ន៎! សព្វដងហ្នឹងឯងទៅទិញផ្កាត្រឡប់មកវិញភ្លាមៗ, ម្តងនេះជាប់ទាក់ទាមដោយកិច្ចអ្វី បានជាយឺតយូរផុតម្ល៉េះ ? នាងខុជ្ជុត្តរា ឆ្លើយថា: ខ្ញុំចេញដំណើរទៅ ជួនជាបានជួបនឹងព្រះសម្មាសម្ពុទ្ធ កំពុងសំដែងធម៌ទេសនា; សេចក្តីធម៌អាថ៌ពីរោះពីសាណាស់ គួរឲ្យចង់ស្តាប់; ខ្ញុំជាប់ស្តាប់ធម៌ទេសនាបានជាអាក់ដំណើរយឺតយូរយ៉ាងនេះ, គុណរឿងនេះ សូមព្រះនាងអភ័យទោស ។ នាងសាមាវតីនឹងស្រីទាំង ៥០០ ឮដំណឹងដូច្នោះក៏ចង់ស្តាប់ដែរ, ប៉ុន្តែទាល់គំនិតនឹងសុំព្រះរាជានុញ្ញាតចេញទៅស្តាប់ផងពុំបាន ទើបអញ្ជើញនាងខុជ្ជុត្តរាឲ្យសំដែងធម៌ទេសនាឲ្យស្តាប់, បានរៀបចំគ្រឿងប្រដាប់គុបតែងទីធម្មាសនៈដ៏ខ្ពង់ខ្ពស់ ឲ្យនាងខុជ្ជុត្តរានោះឡើងអង្គុយសំដែងធម៌ទេសនា ។ កាលបើនាងសាមាវតី នឹងស្រីទាំង៥០០ ស្តាប់បាន មានសេចក្តីជ្រះថ្លា, ក៏ធ្វើនាងខុជ្ជុត្តរាឲ្យជាអ្នកជា រួចខ្លួនអំពីនាទីជាទាសី ហើយតាំងនាង

ខុទ្ទកទៀតជាអាចារ្យសម្រាប់បង្រៀនធម៌និងសំដែងធម៌ឲ្យស្តាប់, បានតាំងបូជាចាន់ខុទ្ទកដោយគ្រឿងសក្ការបូជាផ្សេងៗ ច្រើនជាអនេក ។

រឿងនេះគួរឲ្យយល់ថា បរិយត្តិធម៌មានគុណអស្ចារ្យក្រៃពេក អាចស្ទួយកុសលបុគ្គលដ៏ជាអ្នកបេះចាំនោះឲ្យអណ្តែតឡើងកាន់ដំណែងដ៏ថ្កុំថ្កើងចំឡែកជាងធម៌ឯទៀតៗ ។

ចាន់ខុទ្ទកដែលបេះសំដែងធម៌ក្តី ទាំងសាមណេរក៏និងស្រីទាំង ៥០០ ដែលចូលចិត្តស្តាប់ធម៌ក្តី បានសម្រេចសោតាបត្តិផលខ្លះ សកទាគាមិ-ផលខ្លះ អនាគាមិផលខ្លះ; លុះលែងជាតិអំពីអត្តភាពនេះទៅ បានទៅកើតក្នុងសុគតិសួគ៌ទេវលោកទាំងអស់គ្នា ។

ហេតុដូច្នេះ បានជាព្រះដ៏ឈ្នះមារទ្រង់ត្រាស់សំដែងថា ធម្មោ បាបេតិ សុគតឹ ធម៌ត្រូវ រមែងនាំសត្វទៅកាន់សុគតិ ។

ចប់ធម៌ត្រូវក្នុងផ្នែកទី ១ ។

ចំណែកខាងធម៌ខុសវិញសោត ក៏មាន ៣ ផ្នែកដូចគ្នានឹងធម៌ត្រូវនេះដែរ; គួរសប្បុរសទាំងឡាយសន្និដ្ឋានថា: ធម៌ខុសនោះគឺបរិយត្តិ-អធម៌ ១ បដិបត្តិអធម៌ ១ បដិវេធអធម៌ ១ ។

**បរិយត្តិអធម៌** ប្រែថា: ធម៌ខុសដែលជនពាលតែងសិក្សាតែងស្តាប់ បានដល់ធម៌ខុសដូចយ៉ាងមន្តអាគមផ្សេងៗ ជាខាងក្រៅព្រះពុទ្ធ-សាសនា មានមន្តសណ្តំ, មន្តស្នេហ៍ផ្ចិតមនុស្សឲ្យរវើរវាយខុសក្រិត្យ

ឋរណ៏, មគ្គបង់ចំណែង; មគ្គផលជាដើម ជាគូប្រតិបក្ខនឹងបរិយត្តិធម៌ ដែលសំដែងរួចមកហើយនេះ ។ ធម៌ខុសទាំងនេះរមែងនាំជនពាលដែលសិក្សាឲ្យសំយុងក្បាលចុះទៅកាន់នរក, សមដូចពុទ្ធភាសិតថា: អធម្មោ និរយំ នេតិ ដូច្នេះពិត ។

ចប់ធម៌ខុសក្នុងផ្នែកទី ១ ។

ធម៌ត្រូវក្នុងផ្នែកទី ២ ហៅថាបដិបត្តិធម៌ ធម៌សម្រាប់ប្រតិបត្តិតាម គឺអដ្ឋង្គិកមគ្គទាំង ៨ ប្រការ មានសម្មាទិដ្ឋិជាដើមដូចបានសំដែងកប់ឈ្មោះគ្រប់ចំនួនរួចមកហើយ ។ អដ្ឋង្គិកមគ្គនេះ មានសេចក្តីប្រាកដក្នុងសុត្តន្តបិដកខ្លះ អភិធម្មបិដកខ្លះ កំណត់ឲ្យឈ្មោះថាសម្មត្តនិយតាធម៌ ប្រែថា "ធម៌ទៀងក្នុងផ្លូវត្រូវឬថាធម៌ប្រាកដជាត្រូវ" ដែលជាគូប្រតិបក្ខនឹងមិច្ឆត្តនិយតាធម៌ ប្រែថា "ធម៌ទៀងក្នុងផ្លូវខុស ឬធម៌ប្រាកដជាខុស" ដូចពុទ្ធភាសិតដែលមានប្រាកដមកក្នុងបទមាតិកាអភិធម្មថា "សម្មត្ត-និយតា ធម្មា មិច្ឆត្តនិយតា ធម្មា" ដូច្នេះជាដើម ។

បដិបត្តិធម៌គឺ អដ្ឋង្គិកមគ្គទាំង ៨ ប្រការនេះ ជាបច្ច័យឲ្យកំឡាំងតៗគ្នា បើបុរសបុគ្គលណាប្រតិបត្តិធ្វើសម្មាទិដ្ឋិសេចក្តីយល់ត្រូវឲ្យកើតឡើងបានហើយ ជាហេតុឲ្យកើតសម្មាសង្កប្បៈ សេចក្តីត្រិះរិះត្រូវជាដើមតមកទៀត ជាលំដាប់រហូតដល់សម្មាសមាធិជាទីបំផុតពុំខាន ។

គន្លងនៃសេចក្ដីប្រតិបត្តិទាំង ៨ ខនេះ ជាធម៌សម្រាប់ផ្ដាច់ផ្ដិលនូវគំនរនៃសេចក្ដីទុក្ខ ហើយប្រមូលយកនូវសេចក្ដីសុខមកប្រគល់ឲ្យ ជាអំណោយដ៏វិសេសជាងអំណោយនៃមនុស្ស ទេវតា មារ ព្រហ្មទាំងពួង, សមដូចពុទ្ធភាសិតថា

ន តំ មាតា បិតា កយិរា អញ្ញេ វាបិ ច ញាតកា
សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ ។

ប្រែថា ប្រយោជន៍គឺសេចក្ដីសុខសេចក្ដីចំរើន ដែលមាតាបិតា ញាតកាធ្វើឲ្យសម្រេចដល់ខ្លួន ឬដល់បងប្អូនពុំបាន នោះមានតែចិត្តដែលបុគ្គលផ្ដងទៀងត្រូវ ហៅថាសម្មាទិដ្ឋិនេះ ទើបអាចធ្វើឲ្យសម្រេចបាន ឬធ្វើឲ្យសម្រេចវិសេសហួសពីនោះទៅទៀតក៏សឹងបាន ដោយឥតទើសទាល់ ។

បណ្ដាជនដែលស្រឡាញ់រាប់អានយើងទាំងប៉ុន្មាន នោះបំផុតត្រឹមលោកអ្នកដ៏មានគុណគឺមាតាបិតាគ្រូអាចារ្យជាដើមប៉ុណ្ណោះ, ប៉ុន្តែទុកជាមាតាបិតាដែលមានបុណ្យច្រើន ដូចមាតាបិតារបស់នាងវិសាខាជាដើម ក៏អាចចែកផលប្រយោជន៍ឲ្យកូនបាន ត្រឹមតែសម្បត្តិដែលខ្លួនមានស្រាប់ប៉ុណ្ណោះ, ដែលនឹងក្រសោបយកសម្បត្តិក្នុងមហាទ្វីបទាំង ៤ មកចែកឲ្យកូនផង នោះពុំបានជាដាច់ខាត ។ បើត្រឹមតែសម្បត្តិមនុស្សក្នុងមហាទ្វីបទាំង ៤ មាតាបិតាប្រមូលយកមកចែកកូនពុំបានទៅហើយ, ចាំបាច់

និយាយថ្វីឡើយដល់សម្បត្តិទេពតាក្នុងឋានសួគ៌ ។ មានតែចិត្តដែលបុគ្គលផ្គងឡើងត្រូវតែសម្មាទិដ្ឋិនេះ ទើបអាចប្រគល់សម្បត្តិមនុស្សក្នុងមហាទ្វីបទាំង ៤ នឹងសម្បត្តិទេពតាក្នុងឋានកាមាវចរសួគ៌ ៦ ជាន់នឹងសម្បត្តិក្នុងព្រហ្មលោក ១៦ ជាន់ ព្រមទាំងលោកុត្តរសម្បត្តិ គឺមគ្គ ផល និព្វាន ឲ្យដល់ជនទាំងពួងបានជាប្រាកដ ។ ហេតុដូច្នេះ បានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា ធម្មោ បាបេតិ សុគតឹ ធម៌ត្រូវរមែងញ៉ាំងសត្វឲ្យដល់នូវសុគតិ គឺផ្លូវណាជនអ្នកប្រតិបត្តិឲ្យមានដំណើរល្អទៅខាងមុខ ។

ចប់ធម៌ត្រូវក្នុងផ្នែកទី ២ ។

ឯធម៌ខុសក្នុងផ្នែកទី ២ ហៅថាបដិបត្តិអធម៌ ដែលជាគូបដិបក្ខនឹងបដិបត្តិធម៌នោះ គឺមាន ៨ ប្រការដូចគ្នាដែរ គឺមិច្ឆាទិដ្ឋិ សេចក្តីយល់ខុស ១, មិច្ឆាសង្កប្បោ សេចក្តីត្រិះរិះខុស ១, មិច្ឆាវាចា វាចាខុស ១, មិច្ឆាកម្មន្តោ ការងារខុស ១, មិច្ឆាអាជីវោ ការចិញ្ចឹមជីវិតខុស ១, មិច្ឆាវាយាមោ សេចក្តីព្យាយាមខុស ១, មិច្ឆាសតិ ស្មារតីខុស ១, មិច្ឆា-សមាធិ ចិត្តដំកល់ខុស ១, ធម៌ទាំង ៨ ប្រការនេះ មានសេចក្តីប្រាកដក្នុងសុត្តន្តបិដកខ្លះ អភិធម្មបិដកខ្លះ កំណត់ឲ្យឈ្មោះថា "មិច្ឆត្តនិយតា-ធម៌" ប្រែថា ធម៌ទៀងក្នុងផ្លូវខុស ឬថាធម៌ប្រាកដជាខុស" ។ បើមិច្ឆា-ទិដ្ឋិ សេចក្តីយល់ខុសមានហើយ ជាបច្ច័យឲ្យកើតធម៌ខុសមានមិច្ឆា-

សង្កប្បា សេចក្ដីត្រិះរិះខុសជាដើម តៗគ្នាជាលំដាប់ រហូតដល់មិច្ឆាសមាធិជាទីបំផុត ។

មិច្ឆាទិដ្ឋិ សេចក្ដីយល់ខុសនោះ ចែកចេញជាប្រភេទយ៉ាងសង្ខេបមាន ២ យ៉ាង; ចែកចេញយ៉ាងកណ្ដាលមាន ៣ ប្រការ ចែកចេញដោយពិស្ដារមាន ៦២ ប្រភេទ ។

ឥឡូវនេះ សូមចែកតែប្រភេទយ៉ាងកណ្ដាលថា : សេចក្ដីយល់ខុសមាន ៣ ប្រការនោះគឺ អកិរិយទិដ្ឋិ សេចក្ដីយល់ឃើញថា អំពើអាក្រក់ដែលគេសន្មតថាបាប ដូចយ៉ាងបៀតបៀនគំរាមអ្នកដទៃដោយអាជ្ញាជាដើមក្ដី ប្រព្រឹត្តល្មើសស្វាមីភរិយារបស់អ្នកដទៃជាដើមក្ដី, និយាយកុហក ទ្រគោះ បោកបោះ សិកសៀត ញុះញង់ជាដើមក្ដី ដែលគេសន្មតថាបាប នោះទុកជាបុគ្គលបានធ្វើហើយ ក៏ហើយៗទៅទេ មិនជាបាបអ្វីទេ, ដូច្នេះ ១; អហេតុកទិដ្ឋិ សេចក្ដីយល់ឃើញថា គ្មានហេតុដែលនាំសត្វឲ្យសៅហ្មង ឬបរិសុទ្ធទេ សត្វទាំងឡាយ សៅហ្មងឯងៗ បរិសុទ្ធឯងៗ ដូច្នេះ ១, នត្ថិកទិដ្ឋិ សេចក្ដីយល់ឃើញថា ឲ្យទានគ្មានផល បូជាគ្មានផល ឬយល់ថា កិច្ចដែលគេសន្មតថាបុណ្យ បើបុគ្គលណាបានធ្វើហើយ ក៏គ្រាន់តែឲ្យមនុស្សពោលសរសើរក្នុងបច្ចុប្បន្នប៉ុណ្ណោះទេ, ដែលនឹងឲ្យផលទៅក្នុងលោកខាងមុខ ដូចសំដីដែលជនពោលថាបញ្ចោរមកនោះ ពុំមានដោយដាច់ខាតដូច្នេះ ១ ។ នត្ថិកទិដ្ឋិ ៣ នេះនឹងហៅថា ទេច្ច-

ទទិដ្ឋិ ដូច្នេះវិញក៏បាន គឺសេចក្ដីយល់ឃើញថា សត្វទាំងឡាយកាល ទម្លាយកាយទៅហើយ សូន្យទទេ វិនាសឈឹង ខាងខាយ អំពីសេចក្ដី ស្លាប់ទៅមិនមានអ្វីទៀតទេ ៗ បុគ្គលណាយល់ដូច្នេះហើយ នោះមុខជា លែងធ្វើបុណ្យ ព្រោះគិតថាមិនដឹងយកបុណ្យទៅប្រើការឯណា ហើយ ឥតញញើតនឹងអំពើបាប ព្រោះគិតឃើញថា បើធ្វើបាប ក៏បាប ឥតតាមទៅផ្ដន្ទាដល់ជាតិណាទៀតដែរ ៗ យោបល់យ៉ាងនេះពេញជា ខុសខ្លាំងណាស់! មានទោសច្រើនជាទីបំផុត! សមដូចព្រះពុទ្ធដីកា ព្រះសម្មាសម្ពុទ្ធ ដែលឃើញប្រាកដក្នុងគម្ពីរអង្គុត្តរនិកាយឯកនិបាត ថា ម្នាលភិក្ខុទាំងឡាយ, តថាគតស្រាវជ្រាវរកអំពើដែលមានទោសច្រើន ដូចមិច្ឆាទិដ្ឋិ មិនឃើញមានសោះ, មានតែមិច្ឆាទិដ្ឋិនេះឯង ដែលមាន ទោសច្រើនជាងគេបំផុត ៗ អម្បាលអនន្តរិយកម្មគឺការសម្លាប់មាតា សម្លាប់បិតា សម្លាប់ព្រះអរហន្ត បំបែកសង្ឃ និងធ្វើលោហិតព្រះ ពុទ្ធឲ្យពុះពង់ឡើង ទាំង ៥ ប្រការនេះ ជាអំពើមានទោសច្រើនដល់ ម្ល៉េះម្ដេចក៏ពុំទាន់ស្មើនឹងទោសនៃមិច្ឆាទិដ្ឋិនៅឡើយ ៗ ព្រោះហេតុអ្វី? ព្រោះតែអនន្តរិយកម្មមានទោសនាំឲ្យចុះនរកកំណត់ត្រឹមមួយកប្បប៉ុណ្ណោះ ឯមិច្ឆាទិដ្ឋិនោះបើជានិយតប្រកាន់ទៀងដូច្នោះហើយ មានទោសនាំឲ្យចុះ នរកកំណត់ជាប៉ុន្មានកប្បពុំបានឡើយ ៗ មិច្ឆាទិដ្ឋិនេះអាចធ្វើបុរស បុគ្គលអ្នកប្រកាន់ខ្ជាប់ ឲ្យវិនាសអន្តរាយជាងសេចក្ដីផ្ដន្ទារបស់មនុស្សនិង

ទេពតាទាំងឡាយទាំងហួសប្រមាណណាស់, សមដូចព្រះពុទ្ធដីកា ព្រះសាស្តាជាម្ចាស់ត្រាស់សំដែងថា

ទិសោ ទិសំ យន្តំ កយិរា វេរី វា បន វេរិនំ
មិច្ឆាបណិហិតំ ចិត្តំ    បាបិយោ នំ តតោ ករេ ។

ចោរហើយនឹងចោរ ជាបុគ្គលមានចិត្តអាក្រក់ក្រៃលែងស្រាប់ ថែមទាំងមានសំអប់គំនុំគុំគ្នាទៅវិញទៅមកទៀត ពុំនោះសោតទេ បុគ្គលមានពៀរ ហើយនឹងបុគ្គលមានពៀរ ដែលធ្លាប់ចងពៀរនឹងគ្នាជាយូរអង្វែងមកហើយ បុគ្គលទាំងពីរពួកនេះ បានជួបប្រទះគ្នាហើយ រមែងធ្វើសេចក្តីវិនាសឲ្យកើតឡើងដល់គ្នានឹងគ្នាយ៉ាងខ្លាំង គឺត្រូវចាក់គ្នាក៏ចាក់ កាប់គ្នាក៏កាប់ បាញ់គ្នាក៏បាញ់ ឬតែងធ្វើឲ្យអន្តរាយដោយឧបាយផ្សេងៗគួរស្បើមពុំខាន, ប៉ុន្តែនៅពុំទាន់ស្មើនឹងចិត្តដែលបុគ្គលដំកល់ខុសនៅឡើយទេ, គឺសេចក្តីយល់ខុសដែលហៅថាមិច្ឆាទិដ្ឋិនោះ អាចធ្វើបុគ្គលអ្នកយល់ខុសនោះឲ្យវិនាសខ្លាំងក្រៃលែងជាងនោះទៅទៀត ព្រោះថាបុគ្គលជាសត្រូវនឹងគ្នាទាំងពីរពួកនេះ ធ្វើសេចក្តីវិនាសឲ្យកើតឡើងត្រឹមតែមួយជាតិ ឬពីរជាតិប៉ុណ្ណោះ, ឯសេចក្តីយល់ខុស អាចធ្វើឲ្យវិនាសក្នុងបច្ចុប្បន្នជាតិនេះផង ឲ្យវិនាសទៅខាងអនាគតកំណត់ជាតិកំណើតថាប៉ុណ្ណោះប៉ុណ្ណោះពុំបានឯណោះទៀតផង គឺថាបើស្លាប់វិនាសពីជាតិនេះទៅ

ទៀងតែទៅកើតក្នុងនរក, សមនឹងពុទ្ធភាសិត ដែលទ្រង់សំដែងថា អធម្មោ និរយំ នេតិ ធម៌ខុសតែងនាំសត្វចុះនរក ។

ចប់ធម៌ខុសក្នុងផ្នែកទី ២ ។

ឯធម៌ត្រូវក្នុងផ្នែកទី ៣ ហៅថាបដិវេធធម៌ ធម៌គឺសេចក្ដីត្រាស់ដឹង របស់ព្រះអរិយបុគ្គលទាំងឡាយ ឬថាធម៌ដែលព្រះអរិយបុគ្គលទាំងឡាយ បានត្រាស់ដឹងផ្ទាល់ខ្លួន ដោយបានប្រតិបត្តិតាមបដិបត្តិធម៌គ្រប់គ្រាន់ ទាំង ៨ ថ្នាក់, គឺថាបុរសបុគ្គលដែលមាន សម្មាទិដ្ឋិ, សម្មាសង្កប្បោ, សម្មាវាចា, សម្មាកម្មន្តោ, សម្មាអាជីវោ, សម្មាវាយាមោ, សម្មាសតិ, សម្មាសមាធិ ហើយចំរើនវិបស្សនាបញ្ញាតទៅទៀត ក៏នឹងបានត្រាស់ដឹងជាក់ច្បាស់នូវបដិវេធធម៌ គឺមគ្គញាណ ៤ ផលញាណ ៤ ជាធម៌ល្អបំផុតថ្នាក់ ដែលហៅថាលោកុត្តរធម៌ដូច្នេះផងក៏បាន ព្រោះធម៌នេះមិនត្រឹមតែធ្វើសត្វឲ្យទៅកាន់សុគតិប៉ុណ្ណោះទេ អាចញាំងសត្វឲ្យឆ្លងផុតចាកលោកទៀតផង ។

ត្រង់ពាក្យថាលោកៗ នេះ បានសេចក្ដីថាប្រទេសដែលប្រកប ដោយសេចក្ដីវិនាស ឬថាប្រទេសដែលត្រូវតែលិចអណ្ដែត លិចអណ្ដែត ចែកចេញជាបីកន្លែងគឺ **កាមលោក** បានដល់ឋាននរក ប្រេត អសុរកាយ តិរច្ឆាន មនុស្សនឹងកាមាវចរសួគ៌ ៦ ជាន់ ១ **រូបលោក** បានដល់ឋានរូបព្រហ្ម ១៦ ជាន់ ១, **អរូបលោក** បានដល់ឋានអរូបព្រហ្ម ៤ ជាន់ ១ ។ ប្រទេសទាំងបីអន្លើនេះ ប្រកបដោយសេចក្ដីវិនាសកល់ទីភពត្រីដូចបណ្ដា

ជនប្រុសស្រីជាមនុស្សជាតិ ដែលកើតមកក្នុងលោកគឺហៅថាមនុស្សនេះ សុទ្ធតែត្រូវតែប៉ះនឹងសេចក្តីវិនាសជាច្រើនប្រការគ្រប់គ្នា គឺអ្នកខ្លះកំពុងតែនៅជាសុខ ស្រាប់តែវិនាសចាកញាតិ, អ្នកខ្លះកំពុងរីករាយជាមួយពួកញាតិស្រាប់តែវិនាសចាកទ្រព្យសម្បត្តិ អ្នកខ្លះទើបតែនឹងសន្សំទ្រព្យសម្បត្តិបានបន្តិចបន្តួចស្រាប់តែវិនាសចាកសេចក្តីសុខ គឺត្រូវរងគ្រោះដោយជម្ងឺឈឺចាប់ ដោយគេចាក់គេកាប់ ដោយគេបណ្តេញបំបរ ដោយគេសង្កត់សង្កិន ឲ្យបាក់បបខ្លបខ្លាចនៅក្រោមអំណាចគេក៏សឹងមាន ៗ កាលបើយ៉ាងដូច្នេះ តើសេចក្តីសុខមាននៅត្រង់ណា ? សេចក្តីវិនាសឬដំណើរលិចអណ្តែតយ៉ាងនេះ រមែងមានជាធម្មតា ក្នុងកន្លែងដែលសត្វកើត ហេតុដូច្នោះ បានជាកន្លែងនោះឈ្មោះថាលោក ៗ ដូច្នេះ ៗ សេចក្តីត្រាស់ដឹង ដែលហៅថាបដិវេធធម៌របស់ក្រុមអ្នកប្រាជ្ញ អាចស្រាយខ្លួនឲ្យរួចផុតចាកលោកទាំងបីនេះទៅប្រតិស្ឋានក្នុងព្រះនិព្វានដែលឥតមានសេចក្តីវិនាសបាន បានជាហៅថា លោកុត្តរធម៌ដូច្នេះផង ៗ បដិវេធធម៌នេះ ជាធម៌ត្រូវធម៌ល្អបណ្តាច់បណ្តូលកំពូលធម៌ទាំងអស់ ៗ

ចប់ធម៌ត្រូវក្នុងផ្នែកទី ៣ ៗ

ចំណែកខាងធម៌ខុសក្នុងផ្នែកទីបី ហៅថាបដិវេធអធម៌ បានដល់សេចក្តីត្រាស់ដឹងខុស បេះខុស គឺសេចក្តីត្រាស់ដឹងខាងការប្រកបខ្លួនក្នុងលោក ធ្វើខ្លួនឯងនឹងផងទាំងពួងឲ្យរងគ្រោះវិនាស, ធម៌ខុស

ជាក់នេះ  ក៏កើតតណ្ហាអំពីបដិបត្តិអធម្មក្នុងជាក់ទីពីរនោះមកដែរ  គឺបុរសបុគ្គលរូបណាដែលមានមិច្ឆាទិដ្ឋិសេចក្តីយល់ខុសហើយ  ប្រាកដជាមានកំហុសតៗគ្នា  ហេតុដល់មិច្ឆាសមាធិ  ការផ្តោតចិត្តស៊ប់នៅក្នុងអារម្មណ៍ណាមួយខុសទៀត,  បើមានការតាំងចិត្តខុសស៊ប់ហើយ  មុខជានឹងកើតបដិវេធអធម៌  គឺសេចក្តីត្រាស់ដឹងខុស  ដែលជាគ្រឿងផ្តើមខ្លួននឹងសត្វតាំងពួងមិនឲ្យរើរួចពីលោកតាំងពីបុរាណជាប្រាកដ ។  ម្យ៉ាងទៀតថា មនុស្សដែលមានបដិវេធអធម៌នេះ  តែងបង្កើតសេចក្តីវិនាសដែលមិនទាន់កើតឲ្យកើតឡើង  តែងបង្កើតសេចក្តីវិនាសដែលកើតមានស្រាប់ហើយឲ្យរីងរឹតតែវិនាសតទៅទៀត,  បុគ្គលនោះស្លាប់ទៅ  ទៀងតែទៅកើតក្នុងនរកទៀត ។

ចប់ធម៌ខុសក្នុងផ្នែកទី ៣ ។

ធម្មាធម្មកថា សង្ខេបេន សមត្តា ការសំដែងអំពីធម៌ត្រូវ ធម៌ខុសសន្មតថាចប់ដោយសង្ខេបប៉ុណ្ណេះ ។

សូមសិរីសួស្តីកើតមានដល់គ្រប់សប្បុរសអ្នកស្តាប់  អ្នកប្រតិបត្តិ តាមទាំងអស់គ្នា សព្វកាលវេលាជាដរាបទៅ ។

សុមង៍